ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣

# សេចក្តីប្រកាសព័ត៌មាន
# កិច្ចប្រជុំលើកទី៨របស់គណៈកម្មាធិការជាតិសម្រាប់ការ
# អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សូមជូនដំណឹងដល់បណ្តាញសារព័ត៌មានទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា គ.ជ.អ.ប នឹងរៀបចំកិច្ចប្រជុំលើកទី៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប។

កិច្ចប្រជុំនេះមានរបៀបវារៈដូចខាងក្រោម៖

1. ពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញការងារនៅថ្នាក់ក្រោមជាតិ
2. ពិភាក្សា និងអនុម័តលើសេចក្តីព្រាងគោលនយោបាយស្តីពីការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សនៅថ្នាក់ក្រោមជាតិ
3. ពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្ទេរធនធាន និងថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់
4. វឌ្ឍនភាពនៃការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសម្រាប់ការអនុវត្តមូលនិធិក្រុង ស្រុក រួមមាន៖
   ក. ប្រកាសស្តីពីនីតិវិធីលទ្ធកម្មក្រុង ស្រុក
   ខ. ប្រកាសស្តីពីប្រព័ន្ធទូទាត់ និងគណនេយ្យថវិកាក្រុង ស្រុក
   គ. ប្រកាសស្តីពីការរៀបចំ អនុម័ត និងអនុវត្តថវិកាក្រុង ស្រុក

5. របាយការណ៍សង្ខេបអំពីវឌ្ឍនភាពនៃកិច្ចដំណើរការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួងស្ថាប័ន
6. ពិភាក្សា និងអនុម័តលើសេចក្តីព្រាងសេចក្តីណែនាំស្តីពីការពិនិត្យមើលឡើងវិញនូវមុខងារ សម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
7. ពិភាក្សា និងអនុម័តលើឯកសារទស្សនទានស្តីពីការអនុវត្តសាកល្បងនៃការផ្ទេរមុខងារ ជាក់លាក់មួយចំនួនក្នុងវិស័យសុខាភិបាល ។

**ទីកន្លែង:** នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ (អគារ S) អាសយដ្ឋានៈ មហាវិថីព្រះនរោត្តម ខណ្ឌចំការមន រាជធានីភ្នំពេញ

**ពេលវេលា:** នៅថ្ងៃទី៣0 ខែឧសភា ឆ្នាំ២០១៣ ចាប់ពីម៉ោង ៨:00 ព្រឹក រហូតដល់ ម៉ោង ៥:00 ល្ងាច

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រីដែលជា អ្នកសារព័ត៌មានទាំងអស់អញ្ជើញចូលរួមយកព័ត៌មានតាមកាលបរិច្ឆេទ និងពេលវេលាខាងលើកុំបីខាន ។

*ព័ត៌មានបន្ថែមសូមទំនាក់ទំនងលេខាធិការដ្ឋាន គ.ជ.អ.ប តាមរយៈលេខទូរស័ព្ទ ០១២ ៧៥៨ ៥២0 E-mail: kimchung@ncdd.gov.kh Website: www.ncdd.gov.kh ។*